ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០២១

នៅក្នុងខែកក្កដានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម តាមបែបគន្លងថ្មី លើវិស័យនៃការងារសំខាន់ៗជាច្រើន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនដោយបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក តាមប្រព័ន្ធវីដេអូ និងបើកសម័យប្រជុំលើកទី៧ ព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីស្តាប់របាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៦ និងលើកទី៧ ព្រមទាំងពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៤ច្បាប់ ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញ បញ្ជូនអគ្គិសនី តង់ស្យុង៥០០គីឡូវ៉ុល ពីខេត្តបាត់ដំបងទៅកាន់ព្រំដែនកម្ពុជា-ថៃ

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញ បញ្ជូនអគ្គិសនី តង់ស្យុង៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅកាន់ព្រំដែនកម្ពុជា-ឡាវ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអគ្គិសនីវៀតណាមនៃសាធារណរដ្ឋសង្គមនិយមវៀតណាម សម្រាប់ធានាលើការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាម

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនឆាយណា ណេសិនណល ហេវី ម៉ាស៊ីនណឺរី ខបភើរេសិន សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងតាតៃ លើអានុភាព ១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់ ពីរាជរដ្ឋាភិបាល និងសេចក្តីព្រាងច្បាប់ចំនួន ០៤ច្បាប់ ពីរដ្ឋសភា

- បានទទួលព្រះរាជក្រឹត្យ សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន១៧ច្បាប់

-កំពុងសិក្សាស្រាវជ្រាវ និងព្រាងឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៧ច្បាប់

- បានធ្វើកំណត់បង្ហាញអនុក្រឹត្យ សេចក្តីសម្រេច របាយការណ៍ និងលិខិតផ្សេងៗចំនួន ១៧ច្បាប់

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចៗ

**២- មុខងារតាមដានការអនុវត្តច្បាប់**

- បានតាមដានការកាត់បន្ថយចំណាយរបស់រាជរដ្ឋាភិបាល និងកញ្ចប់ថវិកាជំរុញសេដ្ឋកិច្ច ព្រមទាំងតាមដាន និងសិក្សាស្រាវជ្រាវការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ៗ

**៣- មុខងារតំណាង**

- បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញចុះបេសកកម្មបំពេញការងារនៅខេត្តកំពង់ឆ្នាំង

- បានរៀបចំ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងនាំយកទៀនព្រះវស្សា និងទេយ្យទានទៅប្រគេនព្រះសង្ឃ ព្រមទាំងនាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួន ចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ប្រជាពលរដ្ឋរងគ្រោះមហន្តរាយផ្សេងៗ ជាពិសេសប្រជាពលរដ្ឋដែលកំពុងមានជំងឺកូវីដ-១៩ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងបានបំពេញការកិច្ចផ្សេងៗទៀតនៅមូលដ្ឋាន រាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន១១២លើក

- បានប្រារព្ធពិធីសូត្រមន្តឆ្លងសាលាមួយខ្នង ដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា និងលោកជំទាវ** ព្រមទាំងនាំយកទេយ្យទាន និងទៀនព្រះវស្សា ទៅប្រគេនព្រះសង្ឃគង់នៅវត្តវិសុទ្ធវង្សរាកណ្តាល ខេត្តកំពង់ចាម

- បាននាំយកអំណោយជូនដល់រដ្ឋបាលខេត្តកោះកុង សម្រាប់ចែកជូនប្រជាពលរដ្ឋកំពុងធ្វើចត្តាឡីស័ក និងជួបការលំបាក ព្រមទាំងនាំយកទេយ្យទាន និងទៀនព្រះវស្សា និងបច្ច័យក្នុងមួយវត្តថវិកាចំនួន៥០ម៉ឺនរៀល ទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាអស់កាលត្រីមាស ព្រមទាំងនាំយកកុំព្យូទ័រ ម៉ាស៊ីនព្រីនធ័រ រទេះជនពិការ សម្ភារការិយាល័យ និងថវិកាមួយចំនួន ដែលជាអំណោយរបស់ **ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា** ប្រគល់ជូនរដ្ឋបាលឃុំដើម្បីបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ នៅខេត្តតាកែវ និងខេត្តពោធិ៍សាត់

- បានរៀបចំ និងចាត់ចែងពិធីបូជាសព និងបុណ្យសព **ឯកឧត្តម សុខ យាត** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភា នៅវត្តសុវណ្ណរង្សី ភូមិលេខ១៤ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង

- បាននាំយកអំណោយរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលមានជំងឺកូវីដ-១៩ចំនួន១៦នាក់ និងកំពុងធ្វើចត្តាឡីស័កចំនួន១៧នាក់

- បានទទួលពាក្យបណ្តឹងចំនួន០៥ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន០២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៥ករណី និងកំពុងពិនិត្យសិក្សាចំនួន០៣ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០២ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន០១ករណី

- បានផលិតទស្សនាវដ្តីប្រចាំខែកក្កដា ឆ្នាំ២០២១ ចំនួន៨០០ក្បាល

- បានធ្វើសាររំលែកទុក្ខជូនឥស្សរជននានាចំនួន០២លើក។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

- បានរៀបចំទឹកតែ និងផ្តល់សេវាក្នុងពិធីជំនួបពិភាក្សាការងារជូនសមាជិកព្រឹទ្ធសភាជាមួយឯកឧត្តមឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឥណ្ឌូនេស៊ី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំមហាសន្និបាតគណៈកម្មាធិការនយោបាយនៃក្រុមសភាជាតិអាយប៉ាកម្ពុជា(AIPA) លើកទី៤២, កិច្ចប្រជុំរបស់គណៈកម្មាធិការសេដ្ឋកិច្ចអាយប៉ាកម្ពុជា(AIPA), កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងសេចក្តីប្រកាសរួមនៃសន្និសីទលើកទី៨ នៃគណៈកម្មការកិច្ចការបរទេសនៃសភាកម្ពុជា-ឡាវ-វៀតណាម(CLV), កិច្ចប្រជុំស្តីពីការជំរុញភាពជាដៃគូសភា ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងឆ្លើយតបចំពោះវិបត្តិកូវីដ-១៩ ក្នុងតំបន់ត្រីកោណអភិវឌ្ឍកម្ពុជា-ឡាវ-វៀតណាម, កិច្ចប្រជុំក្រុមសមាជិកសភាស្ត្រីវ៉ាយប៉ាកម្ពុជា(WAIPA), កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការសង្គម និងវប្បធម៌នៃសភាតំបន់អាស៊ី(APA) ព្រមទាំងចូលរួមសិក្ខាសាលាស្តីពី ការស្តារឡើងវិញពីជំងឺកូវីដ-១៩

តាមរយៈចក្ខុវិស័យសិទ្ធិមនុស្ស " តើសភាបានចូលរួមចំណែកអ្វីខ្លះ? " តាមប្រព័ន្ធវីដេអូ

- បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈ (MOU) រវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានរដ្ឋសភាជាមួយវិទ្យាស្ថានសភាអាស៊ី (PCA)

- បានរៀបចំកម្មវិធីកិច្ចសន្ទនាអនឡាញស្តីពី ខួប៦៣ឆ្នាំ ទំនាក់ទំនងការទូតកម្ពុជា-**ចិន** រវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងស្ថានទូតចិនប្រចាំកម្ពុជា និងសមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១០ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែកក្កដាចំនួន០១ច្បាប់

- បានផលិតព័ត៌មានច្បាប់ជាតិ-អន្តរជាតិចំនួន៣០អត្ថបទ

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតឥណ្ឌា, ស្ថានទូតចិន, ស្ថានទូតហ្វីលីពីន, ទីស្តីការគណៈរដ្ឋមន្ត្រី, មូលនិធិចិនដើម្បីសន្តិភាព និងការអភិវឌ្ឍ, សហគមន៍ស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ច (CDC), វិទ្យាស្ថានសភាអាស៊ី(PCA), វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានសាន់ហ៉យស៍, វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(NIPTICT), ក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានទទួលលិខិតចូលចំនួន៦៥៣ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៤០ច្បាប់

- បានរៀបចំបញ្ជីឈ្មោះមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលមានជំងឺកូវីដ-១៩ និងជាសះស្បើយចំនួន១១នាក់

- បានធ្វើបច្ចុប្បន្នភាពផែនការអាទិភាព និងកម្មវិធីការងារឡើងវិញយោងតាមបរិបទកូវីដ-១៩ ដែលនៅបន្តបង្កើតការប្រឈមថ្មី ស្មុគស្មាញ ហើយសម្រាប់កិច្ចបន្តដំណើរការរួមលើធនធានថវិកាត្រូវមាន៥០% តិចជាងមុន និងត្រូវធ្វើវិចារណកម្មឡើងវិញទាំងស្រុងដោយផ្តោតតែលើការងារសំខាន់បំផុត ប្រញាប់បំផុត និងចាំបាច់បំផុត

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន

ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការចែកផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន

- ការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភាឆ្នាំ២០២១

- បានប្រជុំកម្រិតបច្ចេកទេសជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីគម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២២

- បានប្រជុំជាមួយក្រុមការងារគ្រប់គ្រងប្រព័ន្ធFMIS តាមប្រព័ន្ធវីដេអូស្តីពី កិច្ចពិភាក្សាកម្រិតបច្ចេកទេស ដើម្បីស្វែងរកជាតុចូល និងលក្ខខណ្ឌពិសេសមួយចំនួនសម្រាប់បន្តការដាក់ឱ្យអនុវត្តនីតិវិធីថ្មីលើការបើកផ្តល់បៀវត្ស

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មី

- បានរៀបចំរបាយការណ៍ចំណូល-ចំណាយថវិកាព្រឹទ្ធសភា ប្រចាំឆមាសទី១ ឆ្នាំ២០២១ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

- បានបើកប្រាក់បៀវត្សប្រចាំខែកក្កដា និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំខែកក្កដា ឆ្នាំ២០២១

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានធ្វើប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភាចំនួន០៦ប័ណ្ណ

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន២៤ច្បាប់

- បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០២វគ្គ មានសិក្ខាកាមចូលរួមចំនួន១៤នាក់

- បន្តសាងសង់អគារ១ខ្នង កម្ពស់៣ជាន់ សម្រាប់ជាការិយាល័យធ្វើការរបស់នាយកដ្ឋានព័ត៌មានវិទ្យា

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ និងផ្កានានាចំនួន០៩ប្លង់ ព្រមទាំងបានដាំដើមម៉ៃសាក់ នៅសួនច្បារចំនួន០៣ដើម

- បានបាំងម្នាងសិលាសម្រាប់ដាក់តាំងរូបព្រះឆាយាល័ក្ខណ៍នៅសាលខាងជើង និងប្តូរហ៊ុងអក្សរនៅសាលប្រជុំពេញអង្គព្រឹទ្ធសភា

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក ត្រួតពិនិត្យដំណើរយន្ត

ត្រួតពិនិត្យសត្វកណ្តៀរ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៨២គ្រឿង/លើក

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលម៉ាស៊ីនកុំព្យូទ័រ Ipad Smart Phone, ដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន៣៥គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន៥៥ប្រធានបទ

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែកក្កដា ឆ្នាំ២០២១ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៨២ច្បាប់

- បានរៀបចំចាត់ចែងជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួ១៣លើក

- បានតុបតែងលម្អ និងតាំងពិព័រណ៍រូបភាពចំនួន០៧លើក

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១១ច្បាប់ ស្មើនឹង៤៦នាក់

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៤៣៧លើក

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២០លើក មានអ្នកចូលរួមចំនួន២១០នាក់

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៧សំណើ

- បានចុះសួរសុខទុក្ខមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលំហែមាតុភាព

ចំនួន០១នាក់

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២១០លីត្រ តាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន១៥សំណើ និងចងក្រងធ្វើជាសៀវភៅចំនួន២៧ក្បាល អស់ក្រដាសចំនួន២២,៧៥០សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន៤៥លើក ស្មើនឹង៥៧នាក់។ បានជួសជុល ប្តូរប្រេងម៉ាស៊ីនរថយន្ត និងឆៀករថយន្ត ចំនួន៦១គ្រឿង ព្រមទាំងបង់ពន្ធផ្លូវរថយន្តសម្រាប់ឆ្នាំ២០២១

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែមិថុនាចំនួន០៤ច្បាប់

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube, Facebook, និង Telegramចំនួន២,៤៨៧លើក

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៦៦លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២៣លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន០៩លើក។

## III-ទិសដៅការងារខែសីហា ឆ្នាំ២០២១

***-បន្តចូលរួមអនុវត្តសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលឱ្យម៉ឺងម៉ាត់ ដើម្បីចូលរួមប្រយុទ្ធប្រឆាំងការរីករាលដាលជំងឺកាចសាហាវកូវីដ-១៩ តាមវិធានការរបស់ក្រសួងសុខាភិបាល។ ចាត់វិធានការជាក់ស្តែង ដើម្បីគ្រប់គ្រងការរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងស្ថាប័ន។***

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៧ច្បាប់ ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់

២-សេចក្ដីព្រាងច្បាប់ស្ដីពី វិសោធនកម្មមាត្រា១៨ថ្មី នៃច្បាប់ស្ដីពី សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

៣-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

៤-សេចក្ដីព្រាងច្បាប់ស្ដីពី ការប្រកួតប្រជែង

៥-សេចក្ដីព្រាងច្បាប់ស្ដីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

៦-សេចក្ដីព្រាងច្បាប់ស្ដីពី វិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្ដីពី ការងារដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧

៧-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានបូកបីស្ដីពី ការត្រៀមបម្រុងអង្ករសង្គ្រោះបន្ទាន់។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារ និងចុះចែកអំណោយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន និងចូលរួមពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុងនានា៖

+ត្រៀមពិធីសម្ពោធសមិទ្ធផលវត្តព្រែកប្រៃ នៅខណ្ឌដង្កោ និងវត្តកោះមេត្តាពោធិវង្ស នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំពិធីជំនួបសវនាការរវាងថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ/អន្តរជាតិ និងអគ្គទូតនានា

-ត្រៀមរៀបចំ និងចូលរួមកិច្ចប្រជុំ និងវេទិកានានា

-ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCA) តាមការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលជំហានដំបូង

-បន្តតាមដានវឌ្ឍនភាពនៃការរៀបចំប្រជុំ វេទិកាសភាអន្តរជាតិនានា ដូចជា ASEP11, AIPA, CLV, APF...

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន

-បន្តអនុវត្តកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្វែងរកជំនួយ និងការបណ្តុះបណ្តាលធនធានមនុស្សពីប្រភពដៃគូនានា និងការចូលរួមមហាសន្និបាត និងវេទិកានានាក្នុងក្របខណ្ឌ IPU, APF, AIPA, ASEP...។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ត្រៀមរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ស្តីពី កិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាមួយរាជបណ្ឌិត្យសភាកម្ពុជា

-ការកែសម្រួលការបែងចែកថវិកាជាថ្មី សម្រាប់អនុវត្តឆមាសទី២ ឆ្នាំ២០២១ ក្រោយពីការធ្វើវិចារណកម្មថវិកា

-ត្រៀមរបាយការណ៍ថវិកាឆមាសទី១ ឆ្នាំ២០២១ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ការកសាងថវិកាឆ្នាំ២០២២ និងការពារគម្រោងថវិកាកម្រិតនយោបាយ

-ការអនុវត្តគោលការណ៍3E's ដើម្បីធានានិរន្តរភាព និងប្រក្រតីភាព ការអនុវត្តថវិកាឆ្នាំ២០២១ រហូតដល់ដំណាច់ឆ្នាំ ដោយផ្តោតតែលើការងារអាទិភាពដែលចាំបាច់បំផុត សំខាន់បំផុត និងបន្ទាន់បំផុត

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែសីហា ឱ្យបានទាន់ពេលវេលា

-បន្តសហការជាមួយក្រុមការងារ (FMIS) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការប្រើប្រាស់ និងបំពាក់សម្ភារប្រជុំតាមប្រព័ន្ធវីដេអូ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ការបណ្តុះបណ្តាលនឹងមានសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងបរិបទ

កូវីដ-១៩នេះ និងឆ្នាំខាងមុខ ហើយអាចសម្រេចយុទ្ធសាស្ត្រគៀរគរជំនួយ DO MORE WITH LESS ឬ LESS IS MORE ក្នុងក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍស្ថាប័នព្រឹទ្ធសភា (២០២១-២០៣០)

-បន្តបណ្តុះបណ្តាលមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ធ្វើការពីចម្ងាយ ប្រជុំពីចម្ងាយ និងរៀនពីចម្ងាយ

-បន្តការដ្ឋានសំណង់អគារកម្ពស់៣ជាន់ និងសិក្សាកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបច្ចេកវិទ្យាព័ត៌មាន

-ត្រៀមរៀបចំចងក្រងសៀវភៅបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំថ្មី

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងការគ្រប់គ្រងការប្រើប្រាស់ Internet

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានា។ល។)

-អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះទាំងអស់ ត្រូវបង្កើន និងពង្រឹងយន្តការការងារតាមប្រព័ន្ធOnline ដើម្បីធានាគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងស័ក្តិសិទ្ធិភាពជូនស្ថាប័នឱ្យបានល្អប្រសើរ

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ICT) គ្រប់វិស័យនៃការងាររបស់ស្ថាប័ន

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-ត្រៀមលក្ខណៈចូលរួមកម្មវិធី និងពិធីបុណ្យជាតិសំខាន់ៗ។

## IV-**សេចក្តីសន្និដ្ឋាន**

ក្នុងខែកក្កដានេះ ស្ថានភាពការរីករាលដាលនៃជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ (កូវីដ-១៩) ដែលកំពុងបន្តអូសបន្លាយ បានធ្វើឱ្យប៉ះពាល់ដល់អាយុជីវិតមនុស្ស សហគមន៍ សេដ្ឋកិច្ចសង្គម និងសុខភាពសាធារណៈ នៅគ្រប់ទិសទីទូទាំងពិភពលោក និងព្រះរាជាណាចក្រកម្ពុជាយើង។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅតែបន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំង និងគ្រប់គ្រងការរាលដាលនៃជំងឺកូវីដ-១៩។ ស្របពេលជាមួយគ្នានេះ អគ្គលេខាធិការដ្ឋាន

មានការងារមមាញឹកជាច្រើនលើមុខងារនីតិកម្ម ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈ-កម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក និងបើកសម័យប្រជុំលើកទី៧ ព្រឹទ្ធសភា នីតិកាលទី៤ បានដោយរលូនៗ ចំពោះមុខងារតំណាង បានបំពេញមុខងាររបស់ខ្លួនបានយ៉ាងល្អប្រសើរ តាមតម្រូវការចាំបាច់ជាក់ស្តែង ប្រកបដោយភាពទទួលខុសត្រូវតាមមុខសញ្ញារៀងៗខ្លួន ដោយផ្តោតការយកចិត្តទុកដាក់ចុះតាមមូលដ្ឋាន ដើម្បីជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន ឈ្វេងយល់អំពីសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងចូលរួមគោរពវិញ្ញាណក្ខន្ធសព និងនាំយកទៀនព្រះវស្សា និងទេយ្យទាន ទៅប្រគេនព្រះសង្ឃ ព្រមទាំងចែកអំណោយជូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត និងកំពុងធ្វើចត្តាឡីស័ក នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។ ស្របពេលជាមួយគ្នានេះដែរ លើមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានខិតខំយ៉ាងសកម្មក្នុងការស្វែងរកដៃគូអភិវឌ្ឍន៍នានា ជាក់ស្តែងបានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MOU) រវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានរដ្ឋសភាជាមួយវិទ្យាស្ថានសភាអាស៊ី(PCA) និងកម្មវិធីកិច្ចសន្ទនាអនឡាញស្តីពី ខួប៦៣ឆ្នាំ ទំនាក់ទំនងការទូតកម្ពុជា-ចិន រវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងស្ថានទូតចិនប្រចាំកម្ពុជា និងសមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន និងចាត់ចែងការចូលរួមកិច្ចប្រជុំត្រៀមCLV, AIPA, WAIPA, APA តាមប្រព័ន្ធអនឡាញ។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមជាមួយវិធានការ "៣កុំ ៣ការពារ" ឱ្យបានល្អប្រសើរ។

ថ្ងៃពុធ ១១កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**